D36.2

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង

ជូនចំពោះ

លោកចៅក្រម យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ

យោង៖ លិខិតរបស់លោក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២

លោកសហចៅក្រមស៊ើបអង្កេតជាតិ
លោកចៅក្រមជាទីរាប់អាន,

ដោយអវត្តមានពីភ្នំពេញមួយសប្តាហ៍មុនពេញ ខ្ញុំ ទើបតែបានដឹងនៅថ្ងៃនេះអំពីខ្លឹមសារនៃលិខិតរបស់លោកចៅក្រមចុះថ្ងៃទី២៧ ខែកុម្ភៈ។

ជាថ្មីម្តងទៀត លោកចៅក្រម បានជំទាស់នឹងអំណាចរបស់ខ្ញុំក្នុងការធ្វើសកម្មភាពក្នុងនាមជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង។

ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានទទួលស្គាល់យ៉ាងច្បាស់លាស់ នៅក្នុងសេចក្តីសម្រេចថ្មីៗរបស់ពួកគេដែលមានអំណះអំណាងយ៉ាងត្រឹមត្រូវ (សេចក្តីសម្រេចទាំងនេះ ត្រូវបានជូនដំណឹងទៅលោកចៅក្រមផងដែរ) ថា នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០៣ និង០០៤ ខ្ញុំ មាន « អំណាចក្នុងការធ្វើសកម្មភាពក្នុងនាមជាអ្នកជំនួសបណ្តោះអាសន្នចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលអវត្តមាន »។

នៅក្នុងសំណុំរឿងដែលបានលើកឡើង ដោយសារអង្គបុរេជំនុំជម្រះ មិនអាចឈានទៅសម្រេចបានលើការខ្វែងយោបល់ដែលបានប្តឹងទៅខ្លួន អង្គបុរេជំនុំជម្រះ ត្រូវបានសន្មតថាទទួលយកតាមសេចក្តីសម្រេចទាំងឡាយរបស់ខ្ញុំ (វិធាន៧២.៤ឃ នៃអ.វ.ត.ក.) ហើយជាផលវិបាក សេចក្តីសម្រេចទាំងនោះ មានអានុភាពអនុវត្តពេញលេញ ហើយក្នុងន័យនេះ សេចក្តីសម្រេចទាំងនេះ ជាធម្មានុរូបត្រូវមានដាក់ឈ្មោះយើងទាំងពីរនាក់ បើទោះបីជាសេចក្តីសម្រេចទាំងនោះ ត្រូវចុះហត្ថលេខាដោយខ្ញុំតែម្នាក់ឯងក៏ដោយ។

D36.2

គោលការណ៍បែបនេះ មានតម្លៃចំពោះគ្រប់សេចក្តីសម្រេចទាំងអស់ដែលខ្ញុំ ត្រូវដាក់ជូនលោកចៅក្រមក្នុងលក្ខខណ្ឌដូចគ្នា នៅក្នុងក្របខ័ណ្ឌនៃការខ្វែងយោបល់របស់យើង។

ជាផលវិបាក ខ្ញុំ សូមលោកចៅក្រមគោរពច្បាប់ និងបញ្ឈប់ការបញ្ជូនជូនខ្ញុំនូវការជូនដំណឹងទាំងឡាយដែលមិនមានមូលដ្ឋានគតិយុត្តិ ហើយដែលប្រហែលជាមានគោលដៅតែមួយគត់គឺធ្វើឲ្យបរាជ័យចំពោះការអនុវត្តបានល្អនៃបេសកកម្មរបស់ខ្ញុំ។

រាជធានីភ្នំពេញ
ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២

Laurent Kasper-Ansermet
សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង